ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..៤៣០៤.អបស/ប្រ.អបស

# ប្រកាស

## ស្តីពី

## បែបបទ និងលក្ខខណ្ឌសម្រាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍ អនុវត្តអនាម័យល្អ ចំពោះចំណីអាហារ នៅកន្លែងប្រើប្រាស់ចុងក្រោយ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស
- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្ត និងសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិតដល់តុបរិភោគ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងការពារសុខភាពមនុស្ស និងធានាអនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមកន្លែងប្រើប្រាស់ចុងក្រោយ ដោយអនុលោមតាមកម្រិតហានិភ័យ ដើម្បីជំរុញឱ្យមានការប្រកួតប្រជែងនៅក្នុងអាជីវកម្មចំណីអាហារ។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅចែងអំពីបែបបទ និងលក្ខខណ្ឌតម្រូវផ្សេងៗដែលក្រសួងសុខាភិបាល ត្រូវអនុវត្តក្នុងការផ្តល់ ការបន្តសុពលភាព ការព្យួរ ឬការដកហូតនូវវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អចំពោះចំណីអាហារ នៅកន្លែងប្រើប្រាស់ចុងក្រោយ។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់គ្រប់គ្រងអនាម័យ និងសុវត្ថិភាពលើសេវាកម្ម និងអាជីវកម្មចំណីអាហារនៅតាមកន្លែងប្រើប្រាស់ចុងក្រោយទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះរួមមាន៖

- **ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ** សំដៅដល់មន្ត្រីត្រួតពិនិត្យចំណីអាហារនៃក្រសួងសុខាភិបាល ដូចដែលមានបញ្ជាក់ក្រោមប្រកាសលេខ០២១១នៃក្រសួងសុខាភិបាល ចុះថ្ងៃទី៣០ខែមិនា ឆ្នាំ២០១១ ស្តីពីតួនាទី ភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន។
- **កាធីរីង(Catering)** សំដៅដល់គ្រឹះស្ថានរៀបចំ រក្សាទុក និងដឹកជញ្ជូនចំណីអាហារទៅដល់អតិថិជននៅនឹងកន្លែង ឬនៅកន្លែងណាមួយ។
- **ស្តង់បម្រើចំណីអាហារ(Food Court)** សំដៅដល់កន្លែងរៀបចំ ចំអិន និងលក់ចំណីអាហារ
- **កន្លែងប្រើប្រាស់ចុងក្រោយ** សំដៅដល់ការប្រើប្រាស់ចុងក្រោយរបស់អ្នកប្រើប្រាស់រួមមានភោជនីយដ្ឋានខ្នាតធំ អាហារដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតតូច អាហារដ្ឋានខ្នាតតូច ស្តង់លក់ចំណីអាហារកង់ទីន ហាងកាហ្វេ ហាងនំប៉័ង អាហារដ្ឋាននៅតាមសាលារៀន មន្ទីរពេទ្យ ស្ថាប័ន និងគ្រឹះស្ថានផ្សេងៗ និងតូបលក់ចំណីអាហារនៅតាមផ្លូវ។
- **គោលការណ៍ណែនាំគ្រឹះ** សំដៅដល់គោលការណ៍ណែនាំគ្រឹះដែលអនុលោមតាមកម្រិតហានិភ័យដែលអាជីវកម្មចំណីអាហារទាំងអស់ ត្រូវតែអនុវត្តតាមជាដាច់ខាតក្នុងចំណោមគោលការណ៍ណែនាំទាំងអស់ដោយអាស្រ័យតាមកម្រិតស្នាដៃដែលសម្រេចបានក្នុងការប្រតិបត្តិគោលការណ៍អនុវត្តអនាម័យល្អ។
- **អាជីវកម្មចំណីអាហារ** សំដៅដល់ការប្រកបមុខរបរទោះរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញដែលប្រតិបត្តិដោយរដ្ឋ ឬដោយឯកជនក្នុងគោលបំណងផលិត កែច្នៃ និងចែកចាយចំណីអាហារ។
- **ប្រតិបត្តិករធុរកិច្ចចំណីអាហារ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវ និងធានាថាអាជីវកម្មចំណីអាហារដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនស្របតាមក្របខណ្ឌច្បាប់។

- **អនាម័យចំណីអាហារ** សំដៅដល់រាល់ស្ថានភាព និងវិធានការសំខាន់ទាំងអស់ ដើម្បីធានានូវអនាម័យ សុវត្ថិភាព និងភាពសមស្របនៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ចំណីអាហារ។
- **សុវត្ថិភាពចំណីអាហារ** សំដៅដល់ការអនុវត្តដំណើរការ ធានាថាចំណីអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ចំណីអាហារនោះ។
- **តារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ** សំដៅដល់តារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ ដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។
- **ការសំអាត** សំដៅដល់ការយកចេញនូវដី ធូលី កា កសំណល់អាហារ ខ្លាញ់ ឬកាកសំណល់ផ្សេងៗទៀត។
- **ការសម្លាប់មេរោគ** សំដៅដល់ការកាត់បន្ថយដោយប្រើសារធាតុគីមី និង/ឬវិធីរូបសាស្ត្រនូវចំនួនមេរោគក្នុងបរិស្ថានឱ្យនៅកម្រិតមួយដែលមិនធ្វើឱ្យចំណីអាហារខូច។
- **ភោជនីយដ្ឋាន** សំដៅដល់គ្រឹះស្ថានផលិតឬចំអិនចំណីអាហារសម្រាប់បម្រើការទទួលទានរបស់អតិថិជនតាមតម្លៃជាក់លាក់ ឬតាមការបញ្ជាទិញ និងដោយមិនកំណត់តាមទំហំទីតាំងឬចំនួនអតិថិជនឡើយ។
- **អាហារដ្ឋាន** សំដៅដល់ទីតាំងផលិត ឬចំអិនចំណីអាហារ សម្រាប់បម្រើអតិថិជនតាមតម្លៃជាក់លាក់ ឬតាមការបញ្ជាទិញដោយមិនកំណត់តាមទំហំទីតាំង ឬចំនួនអតិថិជនឡើយ។
- **ភោជនីយដ្ឋានខ្នាតធំ** សំដៅដល់ភោជនីយដ្ឋានដែលមានលក្ខណៈដូចខាងក្រោម:

  ១-ទីតាំងស្ថិតក្នុងសណ្ឋាគារ ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម មជ្ឈមណ្ឌលកំសាន្ត រមណីយដ្ឋាន កាស៊ីណូ រោងចក្រ សហគ្រាស អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស និងគ្រឹះស្ថានបណ្តុះបណ្តាល។

  ២-ភោជនីយដ្ឋានប្រណិតត្រូវមានលក្ខណៈសម្បត្តិណាមួយដូចចំណុចខាងក្រោមៈ

  -ទីតាំងសមស្រប

  -បរិស្ថានល្អ

  -ការរចនាមានលក្ខណៈប្រណិត

  -បន្ទប់បរិភោគមានផាសុកភាព

  -កន្លែងចំអិនអាហារបំពាក់ដោយឧបករណ៍ សម្ភារទំនើប

  -សម្ភារ សង្ហារឹមទំនើប

  -បន្ទប់ទឹកមានចំនួនគ្រប់គ្រាន់ និងមានអនាម័យតាមស្តង់ដារ។

  ៣-គ្រឹះស្ថានផលិតចំណីអាហារ នំភេសជ្ជៈ ដែលមានទីតាំងសមស្រប និងបំពាក់ឧបករណ៍ សម្ភារទំនើប ឬមានពាណិជ្ជនាមតែមួយដែលមានពហុសាខា។
- **អាហារដ្ឋានខ្នាតធំ** សំដៅដល់ប្រភេទអាហារដ្ឋានដែលមានទីតាំងនៅក្នុងរោងចក្រ សហគ្រាស មន្ទីរពេទ្យ មជ្ឈមណ្ឌលពាណិជ្ជកម្ម មន្ទីរពហុព្យាបាល គ្រឹះស្ថានសិក្សា អាកាសយានដ្ឋាន។
- **ភោជនីយដ្ឋានខ្នាតតូច** សំដៅដល់ប្រភេទភោជនីយដ្ឋានដែលមិនមានលក្ខណៈដូចភោជនីយដ្ឋានខ្នាតធំ។
- **អាហារដ្ឋានខ្នាតតូច** សំដៅដល់ប្រភេទអាហារដ្ឋានដែលមិនមានលក្ខណៈដូចអាហារដ្ឋានខ្នាតធំ។

**ប្រការ៥ .–**

ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ និងត្រូវដាក់ពាក្យសុំនៅក្រសួងសុខាភិបាល។ ចំពោះភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំ ដែលមានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អហើយ ពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់អនាម័យទេ។

សម្រាប់ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំទាំងអស់ ត្រូវមានអ្នកទទួលខុសត្រូវផ្នែកអនាម័យ និងសុវត្ថិភាពចំណីអាហារយ៉ាងតិចមួយរូបដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពីអនាម័យ សុវត្ថិភាពចំណីអាហារដែលទទួលស្គាល់ពីក្រសួងសុខាភិបាល។

**ប្រការ៦ .–**

ប្រតិបត្តិករធុរកិច្ចចំណីអាហារនឹងត្រូវផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ដោយផ្អែកតាមកម្រិតនៃភាពអនុលោមតាមតារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ ដូចដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសនេះ។ ចំណាត់ថ្នាក់ដែលនឹងត្រូវផ្តល់ជូន និងទទួលស្គាល់ដោយក្រសួងសុខាភិបាលមានដូចខាងក្រោម:

- វិញ្ញាបនបត្រ " ចំណាត់ថ្នាក់ A ៖ ល្អប្រសើរ " គឺផ្តល់ឱ្យដល់ប្រតិបត្តិករធុរកិច្ចចំណីអាហារទាំងឡាយណាដែលអនុលោមបានស្មើ ឬលើសពី៨០ភាគរយ នៃលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងតារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ
- វិញ្ញាបនបត្រ " ចំណាត់ថ្នាក់ B ៖ ល្អ " គឺផ្តល់ឱ្យដល់ប្រតិបត្តិករធុរកិច្ចចំណីអាហារទាំងឡាយណាដែលអនុលោមបានស្មើ ឬលើសពី៧០ភាគរយ នៃលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងតារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ
- វិញ្ញាបនបត្រ " ចំណាត់ថ្នាក់ C ៖ ល្អបង្គួរ " គឺផ្តល់ឱ្យប្រតិបត្តិករធុរកិច្ចចំណីអាហារទាំងឡាយណាដែលអនុលោមបានស្មើ ឬលើសពី៦០ភាគរយ នៃលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងតារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ។

ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំណាដែលខកខានមិនអនុលោមតាមគោលការណ៍ណែនាំគ្រឹះណាមួយនៅក្នុងតារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារនឹងបាត់បង់សិទ្ធិទទួលបានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អទាំង៣ប្រភេទខាងលើនេះ ទោះបីជាតាមរយៈការគណនាសូចនាករនៃការអនុវត្តរបស់ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំបានគោរពតាមលក្ខខណ្ឌផ្សេងៗទៀតក្នុងកម្រិតណាមួយក៏ដោយ។

**ប្រការ៧ .–**

ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ត្រូវធ្វើទៅតាមទម្រង់សមស្របមួយដែលបានកំណត់ដោយក្រសួងសុខាភិបាល និងត្រូវដាក់ដោយប្រតិបត្តិករធុរកិច្ចចំណីអាហារទៅក្រសួងសុខាភិបាលតាមរយៈនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៨ .–**

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អមានទំហំក្រដាស A4 និងមានហត្ថលេខា និងត្រា របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬអ្នកតំណាងស្របច្បាប់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

វិញ្ញាបនបត្រនេះត្រូវមានព័ត៌មានដូចខាងក្រោមៈ

-ឈ្មោះ និងរូបថតរបស់ប្រតិបត្តិករធុរកិច្ចចំណីអាហារ

-ឈ្មោះ និងទីតាំងរបស់ភោជនីយដ្ឋាន ឬអាហារដ្ឋាន

-មានពាក្យ " វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ "

-ឈ្មោះរបស់អ្នកចុះហត្ថលេខា

-ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់វិញ្ញាបនបត្រ និងរយៈពេលមានសុពលភាពនៃវិញ្ញាបនបត្រ។

ស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ភោជនីយដ្ឋានខ្នាតធំនិងអាហារដ្ឋានខ្នាតធំមានលក្ខណៈដូចខាងក្រោមៈ

ជាបន្ទះប្លាស្ទីកមានទទឹង ៤០ សម និងបណ្តោយ ៥២ សម ព័ទ្ធជុំវិញដោយខ្សែបរិមាត្រពណ៌លឿង ហើយចែកជាពីរផ្នែកៈ

ក. ផ្នែកខាងលើមានផ្ទៃពណ៌លឿងទំហំ ៤០ សម គុណ ១០.៦៥ សម និងសរសេរអក្សរៈ

១. និមិត្តសញ្ញាក្រសួងសុខាភិបាលនៅផ្នែកខាងឆ្វេង និងក្រសួងសុខាភិបាល និងសរសេរជាភាសាអង់គ្លេស " **MINISTRY OF HEALTH** " ស្ថិតនៅកណ្តាល

២. នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងសរសេរជាភាសាអង់គ្លេស " **DEPARMENT OF DRUGS AND FOOD** " ស្ថិតនៅចំកណ្តាល

៣. វិញ្ញាបនបត្រលេខនៅផ្នែកខាងស្តាំ

ខ. ផ្នែកខាងកណ្តាលមានផ្ទៃពណ៌ខៀវ(ទឹកប៊ិច)មានទំហំ ៤០.១៣ សម គុណ ៣៧.៥៩ សម មានសរសេរអក្សរៈ

១. "គោលការណ៍អនុវត្តអនាម័យល្អ" និងភាសាអង់គ្លេស"**GOOD HYGIENE PRACTICE** "

២. មានអក្សរស្ថិតក្នុងរង្វង់បញ្ជាក់ពីចំណាត់ថ្នាក់នៃការអនុវត្តអនាម័យ អមដោយស្លាបព្រាមួយ និងសមមួយ។

គ. ផ្នែកខាងក្រោមមានផ្ទៃពណ៌លឿងទំហំ ៤០ សម គុណ ៥.៩ សម និងសរសេរអក្សរៈ

១. ឈ្មោះភោជនីយដ្ឋាន និងអាស័យដ្ឋាន ស្ថិតនៅខាងឆ្វេង

២. កាលបរិច្ឆេទ និងថ្ងៃ ខែ ឆ្នាំផុតកំណត់របស់ស្លាកសញ្ញា ស្ថិតនៅខាងស្តាំ។

ទម្រង់ និងគំរូពិស្តារនៃវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ កំណត់ដោយក្រសួងសុខាភិសុខាភិបាល។

វិញ្ញាបនបត្របញ្ជាក់គោលអនុវត្តអនាម័យល្អ និងស្លាកសញ្ញានេះ ត្រូវដាក់តាំងបង្ហាញនៅក្នុងបរិវេណរបស់ភោជនីយដ្ឋាន ឬអាហារដ្ឋានដែលឱ្យសាធារណៈជនមើលឃើញ។

**ប្រការ៩ .-**

នីតិវិធីទាំងអស់នៃការត្រួតពិនិត្យការស្នើសុំ ត្រូវធ្វើឱ្យចប់រួចរាល់ក្នុងរយៈពេលមិនលើសពី១០ថ្ងៃនៃថ្ងៃធ្វើការគិតចាប់តាំងពីថ្ងៃដែលពាក្យសុំ និងឯកសារពាក់ព័ន្ធទាំងអស់បានដាក់ត្រឹមត្រូវ និងពេញលេញដោយប្រតិបត្តិករធុរកិច្ចចំណីអាហារ។

សេចក្តីសម្រេចក្នុងការផ្តល់ ឬបដិសេធមិនផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ត្រូវធ្វើឡើងដោយក្រសួងសុខាភិបាលក្នុងរយៈពេល ២០ ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលប្រតិបត្តិករធុរកិច្ចចំណីអាហារបានដាក់ពាក្យសុំមានឯកសារពាក់ព័ន្ធពេញលេញ និងត្រឹមត្រូវរួចហើយ។

**ប្រការ១០ .-**

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អមានសុពលភាព ២ ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខារបស់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល។

ប្រតិបត្តិករធុរកិច្ចចំណីអាហារ អាចដាក់ពាក្យសុំបន្តសុពលភាពវិញ្ញាបនបត្រនេះជារៀងរាល់២ឆ្នាំម្តង ដោយត្រូវធ្វើឡើងក្នុងអំឡុងពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ មុនផុតកំណត់សុពលភាពរបស់វិញ្ញាបនបត្រនេះ ដើម្បីធានាថាការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដំណើរការដោយមានវិញ្ញាបនបត្រស្របច្បាប់។

**ប្រការ១១ .-**

ការបង់ថ្លៃលើការដាក់ពាក្យសុំ ការផ្តល់ និងការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អនិងសេវាផ្សេងៗទៀតរួមទាំងស្លាកសញ្ញា(Logo)ដែលពាក់ព័ន្ធ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបន្ទុករបស់ប្រតិបត្តិករធុរកិច្ចចំណីអាហារ។

**ប្រការ១២ .-**

បុគ្គលដែលក្លែងបន្លំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ឬស្លាកសញ្ញា ដែលមានចែងនៅក្នុងប្រកាសនេះ ត្រូវទទួលទោសតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលមានជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៣ .-**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារមានតួនាទី និងសិទ្ធិអំណាច ដើម្បីចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពចំណីអាហារយោងតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងសុខាភិបាល។

**ប្រការ១៤ .-**

ការចុះត្រួតពិនិត្យអនាម័យ សុវត្ថិភាពចំណីអាហារមានជាអាទិ៍ៈ

-អាជីវកម្មចំណីអាហារ និងការតម្លើងឧបករណ៍ និងបរិស្ថាននៅជុំវិញក៏ដូចជាមធ្យោបាយដឹកជញ្ជូន សម្ភារ និងឧបករណ៍នានា

-គ្រឿងផ្សំចំណីអាហារ សារធាតុបន្ថែម សារធាតុគីមីសម្លាប់មេរោគ និងសារធាតុឬជំនួយការដទៃទៀតដែលប្រើក្នុងផលិតកម្ម ការកែច្នៃ ឬការរៀបចំចំណីអាហារ

-បុគ្គលិកធ្វើការនៅក្នុងអាជីវកម្មចំណីអាហារ
-សម្ភារវេចខ្ចប់
-ការសម្អាត ការសម្លាប់មេរោគ និងការថែទាំនៅកន្លែងធ្វើអាជីវកម្មចំណីអាហារ
-ការបិតស្លាកសញ្ញាលើគ្រឿងផ្សំចំណីអាហារ
-ឯកសារទាក់ទងនឹងសុវត្ថិភាពចំណីអាហារ។

**ប្រការ១៥ .-**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវមានសិទ្ធិអំណាច ដើម្បីត្រួតពិនិត្យនិងធ្វើការវាយតម្លៃលក្ខខណ្ឌតម្រូវអនាម័យ និងសុវត្ថិភាពចំណីអាហារដូចមានចែងនៅក្នុងប្រកាសនេះ។

នៅពេលចុះបំពេញភារកិច្ច ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវស្លៀកពាក់ឯកសណ្ឋានដូចមានចែងតាមបទប្បញ្ញត្តិជាធរមានរបស់ក្រសួងសុខាភិបាល ដែលអាចមើលឃើញឈ្មោះ សញ្ញាស័ក្តិ និងមួកយ៉ាងច្បាស់លាស់ ក្នុងម៉ោងប្រតិបត្តិការអាជីវកម្មនឹងត្រូវមានប្រតិបត្តិករធុរកិច្ចចំណីអាហារ ឬអ្នកតំណាងរបស់ប្រតិបត្តិករធុរកិច្ចចំណីអាហារទៅជាមួយ។

**ប្រការ១៦ .-**

ប្រសិនបើអាចធ្វើទៅបាន ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវផ្តល់ដំណឹងជាមុនពីការត្រួតពិនិត្យចំណីអាហារនៅតាមកន្លែងប្រើប្រាស់ចុងក្រោយដែលពាក់ព័ន្ធ។

ការចុះត្រួតពិនិត្យដោយមិនបានព្រៀងទុក ដើម្បីធានាពីការមិនផ្លាស់ប្តូរនៃកម្រិតអនុលោមតាម ត្រូវធ្វើឡើងដោយភ្នាក់ងារត្រួតពិនិត្យចំណីអាហារ អាស្រ័យលើការវាយតម្លៃនៃហានិភ័យ ដោយមិនចាំបាច់មានការជូនដំណឹងជាមុនឡើយ។

**ប្រការ១៧ .-**

ត្រូវបានចាត់ទុកជានិរាករណ៍នូវប្រកាសរបស់ក្រសួងសុខាភិបាលមានដូចតទៅ:

-ប្រកាសលេខ១៣០៩ អបស/ឱអបស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីបែបបទនិងលក្ខខណ្ឌសំរាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ នៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន។

-ប្រកាសលេខ ៨៥៨ អបស/ឱអបស ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលប្រការ១ ប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៩ ប្រការ១៣ របស់ប្រកាសលេខ១៣០៩ អបស/ឱអបស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីបែបបទ និងលក្ខខណ្ឌសំរាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ នៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន។

**ប្រការ១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលចែងផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩ .-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការ"
- -សាលារាជធានី-ខេត្ត
- -ដូចក្នុងប្រការ១៩
- -សមាគមភោជនីយដ្ឋាន"ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ និងកាលប្បវត្តិ